# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កិច្ចព្រមព្រៀង
### ព្យួរកិច្ចសន្យាការងារនៃ ក្រុមហ៊ុន ហៃ ឡុង ហ្វា អ៊ីស្ត ឌីវេឡុបម៉ិន (ខេមបូឌា)

ឆ្នាំពីរពាន់ម្ភៃបួន ខែមករា ថ្ងៃទីម្ភៃបី (២៣) វេលាម៉ោង ០៧:១៥ ព្រឹក នៅបន្ទប់ប្រជុំក្នុង ហៃ ឡុង ហ្វា អ៊ីស្ទឺវេឡុបម៉ិន (ខេមបូឌា) ដែលមានទីតាំងស្ថិតនៅភូមិស្រែញ៉ែរ សង្កាត់ពងទឹក ខណ្ឌដង្កោ រាជធានីភ្នំពេញ ក្រោមអធិបតីភាព លោក ចឹក បឿន ជាប្រធានរដ្ឋបាល បានបើកកិច្ចប្រជុំមួយស្តីពី ការព្យួរកិច្ចសន្យាការងារកម្មកររយៈពេល២៩ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤ ចំនួន១២៥នាក់ ស្រី៦០នាក់ ប្រុស៦៥ នាក់ក្នុងចំណោមកម្មករ និយោជិតសរុបចំនួន ១៤២នាក់ (ស្រី៦៩នាក់) ។

១-សមាសភាពចូលរួម

-តំណាងក្រុមហ៊ុន

| | |
|---|---|
| លោក ចឹក បឿន | ជាប្រធានរដ្ឋបាល |

-តំណាង កម្មករ និយោជិត

| | |
|---|---|
| លោក វ៉ាត វ៉ាន់ថាវ៉ាត | ជាប្រតិភូបុគ្គលិក |
| លោក ស្រី ផូ ភា | ជាលេខាធិការិនី |
| លោក សំ វិទ្ធា | ជាប្រតិភូបុគ្គលិក |
| លោក ភី ភាព | ជាប្រធានសហជីព |

លោក ចឹក បឿន ជាប្រធានរដ្ឋបាល នៃក្រុមហ៊ុន ហៃ ឡុង ហ្វា អ៊ីស្ត ឌីវេឡុបម៉ិន មានប្រសាសន៍ថា យោងតាមភាពចាំបាច់នៃការដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន កម្មករត្រូវបានព្យួរកិច្ចសន្យាការងារដោយមូលហេតុក្រុមហ៊ុនមិនមានអតិថិជនគ្រប់គ្រាន់សម្រាប់ការផលិតដោយសារតែផលប៉ះពាល់នៃវិបត្តិសេដ្ឋកិច្ចពិភពលោក ។

យើងខ្ញុំជាប្រតិភូបុគ្គលិកពេញសិទ្ធិទាំងអស់ នៃក្រុមហ៊ុន ហៃ ឡុង ហ្វា អ៊ីស្ត ឌីវេឡុបម៉ិន ឯកភាពចំពោះការព្យួរកិច្ចសន្យាការងារនេះ ។

២-ការទូទាត់ប្រាក់ឧបត្ថម ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ

ក- ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថមចំនួន៤៥ដុល្លារអាមេរិក ។

ខ- ប្រាក់ឧបត្ថមចំនួនចំនួន ៤៥ដុល្លារ (អាមេរិក) នឹងត្រូវបើកជូននៅថ្ងៃទី០៥ ខែមិនា ឆ្នាំ២០២៤ តាមធនាគារ វឌ្ឍនៈ ។

កិច្ចប្រជុំនេះបានចប់សព្វគ្រប់នៅម៉ោង ០៨ និង០០នាទីព្រឹក នៅថ្ងៃខែឆ្នាំដដែល ។

ហែឡុង ថ្ងៃទី០៨ខែកុម្ភៈឆ្នាំ២០២៤

តំណាងកម្មករ និយោជិត

តាំណាងក្រុមហ៊ុន

HUI LONG FAR EAST DEVELOPMENT (CAMBODIA) Co., Ltd.

KINGDOM OF CAMBODIA